ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ឯកសារជំនួយស្មារតី

## សម្រាប់

## ការពិនិត្យបញ្ជីឈ្មោះ

## និងការចុះឈ្មោះបោះឆ្នោត

ឆ្នាំ២០១៨

# មាតិកា


គោលបំណង ........................................................................................................................ ១

I. ការិយាល័យចុះឈ្មោះបោះឆ្នោត និងការិយាល័យបោះឆ្នោត២

១. ការិយាល័យចុះឈ្មោះបោះឆ្នោត និងរយៈពេលនៃការចុះឈ្មោះបោះឆ្នោត ........................................ ២

ក. ការិយាល័យចុះឈ្មោះបោះឆ្នោត ........................................................................................ ២

ខ. ការិយាល័យបោះឆ្នោត ........................................................................................................ ២

គ. បរិវេណខាងក្នុង និងបរិវេណខាងក្រៅនៃការិយាល័យចុះឈ្មោះបោះឆ្នោត (ក្រៅពីសាលាឃុំ សង្កាត់)......... ២

២. ការបិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត និងការិយាល័យបោះឆ្នោត ......................... ៣

៣. ការបិទផ្សាយបញ្ជីបោះឆ្នោតចុងក្រោយ ................................................................................ ៣

៤. តំនួសតាងស្តីពីរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ......................................... ៣

៥. ការទទួលខុសត្រូវលើការងារសន្តិសុខសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត.................... ៣

II. សម្ភារសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត.................................................. ៤

១. សម្ភារបម្រើឱ្យការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ ២០១៨........................................ ៤

២. របៀបប្រើប្រាស់ក្តារចុច Unicode Standard សម្រាប់ Window7 ................................................. ៦

៣. របៀបរក្សាទុកសម្ភារចុះឈ្មោះបោះឆ្នោត............................................................................. ៦

III. តួនាទី និងភារកិច្ចរបស់ ក.ច.ប ........................................................................................ ៧

១. តួនាទី និងភារកិច្ចរបស់ ក.ច.ប .......................................................................................... ៧

២. ប្រព័ន្ធសុវត្ថិភាព និងរបៀបផ្លាស់ប្តូរលេខសម្ងាត់ (Security Login)............................................. ៧

៣. របៀបផ្លាស់ប្តូរលេខសម្ងាត់ និងបញ្ចូលស្នាមម្រាមដៃ.............................................................. ៨

៤. របៀប Login ប្រព័ន្ធសុវត្ថិភាពតាមរយៈផ្តិតស្នាមម្រាមដៃ ......................................................... ១០

IV. ភាពមានសិទ្ធិចុះឈ្មោះបោះឆ្នោត.................................................................................... ១១

១. លក្ខខណ្ឌដើម្បីមានសិទ្ធិចុះឈ្មោះបោះឆ្នោត ........................................................................ ១១

២. ឯកសារសម្រាប់ប្រើប្រាស់ក្នុងការសុំចុះឈ្មោះបោះឆ្នោត ............................................................ ១២

V. ដំណើរប្រព្រឹត្តទៅនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត.............................................. ១២

១. ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៨ ....................................................... ១២

២. ជំហានទាំង៤ នៃការចុះឈ្មោះបោះឆ្នោត ............................................................................. ១៣

៣. ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត តាមករណីនីមួយៗ ............................................. ១៦

ក. ករណី ពុំមាន អ.ខ ឬមាន អ.ខ ប៉ុន្តែពុំមានលក្ខខណ្ឌគ្រប់គ្រាន់........................................................ ១៦

ខ. ករណីអ្នកសុំចុះឈ្មោះបោះឆ្នោត បានចុះឈ្មោះបោះឆ្នោតរួចហើយ ប៉ុន្តែឈ្មោះ ឬ/និងទិន្នន័យក្នុងបញ្ជីបោះឆ្នោតកត់ត្រាមិនត្រឹមត្រូវ ................ ១៧
គ. ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតមាន អ.ខ ឬ ឯ.អ និងធ្លាប់បានចុះឈ្មោះបោះឆ្នោតរួចហើយ ................ ១៩
ឃ. ករណីសុំចុះឈ្មោះបោះឆ្នោត បានចុះឈ្មោះបោះឆ្នោតរួចហើយ ក្នុងឃុំ សង្កាត់ផ្សេង ................ ២០
ង. ករណីអ្នកសុំចុះឈ្មោះបោះឆ្នោត បានចុះឈ្មោះបោះឆ្នោតរួចហើយ នៅឃុំ សង្កាត់ផ្សេង ក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ................ ២១
ច. ករណីអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោត បានទទួលមរណភាពក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ................ ២១
ឆ. ការអនុវត្តរបស់ គ.ច.ប លើរបាយការណ៍ស្ដីពីការស្រង់ឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោត ................ ២២

VI. របៀប Backup សម្រាប់រក្សាទុកក្នុងកុំព្យូទ័រ ................ ២២

VII. របៀប Backup សម្រាប់បញ្ជូនតាម OwnCloud ទៅឱ្យ គ.ជ.ប ................ ២៥

VIII. គំនូសបំព្រួញរយៈពេលនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងក្នុងដំណាក់កាលនៃការចុះឈ្មោះបោះឆ្នោត ................ ២៨

IX. ការប្រើប្រាស់ទម្រង់បែបបទ ................ ២៨

X. ការវេចខ្ចប់កញ្ចប់ «ក» ដាក់ក្នុងស្បោង «ខ» ដើម្បីបញ្ជូន និងប្រគល់ជូន លធ.ខប ................ ៤៦
១. ការវេចខ្ចប់កញ្ចប់ «ក» តាមការិយាល័យនីមួយៗ ................ ៤៦
២. ការវេចខ្ចប់កញ្ចប់ដាក់គល់សន្លឹកទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះដែលបានប្រើហើយ និងនៅសល់មិនទាន់ប្រើសរុបក្នុងឃុំ សង្កាត់ ................ ៤៥
ក. កញ្ចប់ដាក់គល់សន្លឹកទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះ ដែលបានប្រើហើយសរុបក្នុងឃុំ សង្កាត់ ................ ៤៧
ខ. កញ្ចប់ដាក់ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះ ដែលនៅសល់មិនទាន់ប្រើសរុបក្នុងឃុំ សង្កាត់ ................ ៤៧
៣. ការវេចខ្ចប់សម្ភារ ឯកសារដាក់ក្នុងស្បោង «ខ» បញ្ជូនទៅ លធ.ខប ................ ៤៨
ក. ការវេចខ្ចប់ស្បោង «ខ» ទី១ ................ ៤៨
ខ. ការវេចខ្ចប់ស្បោង «ខ» ទី២ និងស្បោង «ខ» បន្តបន្ទាប់ ................ ៤៩
៤. ការបញ្ជូនស្បោង «ខ» ទៅ លធ.ខប ................ ៤៩
៥. ការត្រួតពិនិត្យស្បោង «ខ» នៅ លធ.ខប និងការវេចខ្ចប់ស្បោង «ខ» ដាក់ក្នុងស្បោង «គ» បញ្ជូនមក ន.គ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត ................ ៥០
ក. ការត្រួតពិនិត្យស្បោង «ខ» នៅ លធ.ខប ................ ៥០

ខ. ការវេចខ្ចប់ស្បោង «គ» បញ្ជូនទៅ ន. គ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត ..................... ៥២
៦. ការវេចខ្ចប់សម្ភារ ឯកសារផ្សេងៗទៀតដែលបានផ្តត់ផ្គង់បម្រើឱ្យការចុះឈ្មោះបោះឆ្នោតបញ្ជូនមក គ.ជ.ប ...... ៥៣
XI. ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូងជាសាធារណៈសម្រាប់គោលដៅនៃការប្តឹងតវ៉ា ឬការប្តឹងជំទាស់ ..... ៥៣
១. ទីកន្លែងបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ..................................................................... ៥៣
២. កាលបរិច្ឆេទនៃការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ..................................................... ៥៤
XII. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ទាក់ទង នឹងបញ្ជីបោះឆ្នោតដំបូង ..................................................................... ៥៤
១. គំនូសបំព្រួញរយៈពេលនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងក្នុងដំណាក់កាលនៃការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ឆ្នាំ២០១៨ ..................................................... ៥៥
ក. ករណីពាក្យបណ្តឹងតវ៉ា ..................................................................... ៥៥
ខ. ករណីពាក្យបណ្តឹងជំទាស់ ..................................................................... ៥៥
២. ការរៀបចំបញ្ជីបោះឆ្នោតផ្លូវការ ..................................................................... ៥៧

# អក្សរកាត់

១. ក្រុមចុះឈ្មោះបោះឆ្នោត ក.ច.ប

២. ក្រុមចុះឈ្មោះបោះឆ្នោតពិសេស ក.ច.ប.ព

៣. ក្រុមប្រឹក្សាឃុំ សង្កាត់ កបឃ.ស

៤. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គ.ជ.ប

៥. ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ច.ប.ត.រ

៦. ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ច.គ.ជ.ប

៧. ទម្រង់បែបបទលេខ ទ.

៨. នាយកដ្ឋាន ន.

៩. បទបញ្ជា និងនីតិវិធី សម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ប្រចាំឆ្នាំ ប.ន.ព.ច

១០. លេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត លធ.ខប

១១. អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ អ.ខ

១២. ឯកសារបញ្ជាក់អត្តសញ្ញាណ ឯ.អ

# គោលបំណង

ឯកសារជំនួយស្មារតីនេះ បានដកស្រង់យកនូវចំណុចគន្លឹះសំខាន់ៗ តាមលំដាប់លំដោយពីបទបញ្ជា និងនីតិវិធី និងសៀវភៅណែនាំសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៨ ដែលត្រូវចាប់ផ្ដើមពីថ្ងៃទី១ ដល់ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៨ ខាងមុខនេះ។

ឯកសារជំនួយស្មារតីនេះ មានគោលបំណងពន្យល់អំពីនីតិវិធីបច្ចេកទេស បទប្បញ្ញត្តិ និងគោលការណ៍សំខាន់ៗនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមប្រព័ន្ធកុំព្យូទ័រ ដើម្បីឱ្យមន្ត្រីបោះឆ្នោត ពិសេស ក.ច.ប និង កបឃ.ស ទាំងអស់សិក្សាស្វែងយល់ និងអនុវត្តការងារតាមតួនាទី ភារកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវ ទាន់ពេលវេលា និងប្រកបដោយលទ្ធផលល្អ។

ឯកសារជំនួយស្មារតីនេះ ក៏ជាជំនួយដ៏សំខាន់សម្រាប់គណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាល អ្នកសង្កេតការណ៍បោះឆ្នោត និងស្ថាប័នពាក់ព័ន្ធទាំងអស់ ដើម្បីសិក្សាស្វែងយល់ និងរួមសហការអនុវត្តតាមតួនាទីភារកិច្ចរបស់ខ្លួន ដើម្បីឱ្យការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៨ នេះ ប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងតម្លាភាព។

# ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៨

## I. ការិយាល័យចុះឈ្មោះបោះឆ្នោត និងការិយាល័យបោះឆ្នោត

### ១. ការិយាល័យចុះឈ្មោះបោះឆ្នោត និងរយៈពេលនៃការចុះឈ្មោះបោះឆ្នោត

#### ក. ការិយាល័យចុះឈ្មោះបោះឆ្នោត

ជាគោលការណ៍ ការិយាល័យចុះឈ្មោះបោះឆ្នោតត្រូវមានទីតាំងនៅ៖

- សាលាឃុំ សង្កាត់
- តាមភូមិមួយចំនួនក្នុងឃុំ សង្កាត់
  - ទីតាំងនៅសាលាឃុំ សង្កាត់ គឺជាការិយាល័យចុះឈ្មោះបោះឆ្នោតចម្បង ដែលត្រូវបើកបម្រើការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ នៅពេលចាប់ផ្តើម និងពេលបញ្ចប់ ដោយប្រើរយៈពេលប្រមាណពាក់កណ្តាលនៃរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតសរុប។
  - ទីតាំងនៅតាមភូមិមួយចំនួនក្រៅពីសាលាឃុំ សង្កាត់ ត្រូវបើកបម្រើការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ដោយប្រើពេលវេលាសរុបមិនឱ្យលើសពីពាក់កណ្តាលនៃរយៈពេលរួមដែលបានកំណត់ឡើយ។

ការិយាល័យចុះឈ្មោះបោះឆ្នោតនីមួយៗ ត្រូវបើកបម្រើការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត សម្រាប់ប្រជាពលរដ្ឋដែលមានសិទ្ធិចុះឈ្មោះបោះឆ្នោតមកពីគ្រប់ភូមិ ក្នុងព្រំប្រទល់ឃុំ សង្កាត់។

#### ខ. ការិយាល័យបោះឆ្នោត

- ការិយាល័យបោះឆ្នោតនីមួយៗ ត្រូវមានប្រជាពលរដ្ឋដែលមានឈ្មោះបោះឆ្នោតយ៉ាងច្រើន ៧៥០នាក់។
- ការិយាល័យបោះឆ្នោតណាមួយ ដែលមានចំនួនអ្នកបោះឆ្នោតលើសពី ៧៥០នាក់ គ.ជ.ប ត្រូវបញ្ចូលឈ្មោះអ្នកដែលលើសនោះទៅក្នុងការិយាល័យបោះឆ្នោតណាមួយក្នុងភូមិជាមួយ ឬការិយាល័យបោះឆ្នោតណាដែលជិតបំផុតនៅក្នុងឃុំ សង្កាត់ ឬអាចបង្កើតការិយាល័យបោះឆ្នោតថ្មីក្នុងភូមិជាមួយ តាមការចាំបាច់។

#### គ. បរិវេណខាងក្នុង និងបរិវេណខាងក្រៅនៃការិយាល័យចុះឈ្មោះបោះឆ្នោត (ក្រៅពីសាលាឃុំ សង្កាត់)




- បរិវេណខាងក្នុង មានកាំប្រវែងយ៉ាងតិច ១៥ម៉ែត្រ។
- បរិវេណខាងក្រៅ មានកាំប្រវែង ១០០ម៉ែត្រ ឬតូចជាងអាស្រ័យដោយស្ថានភាពទីតាំងជាក់ស្តែង ឬមានទម្រង់ផ្សេងពីនេះ។

### ២. ការបិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត និងការិយាល័យបោះឆ្នោត

- កបឃ.ស ត្រូវបិទផ្សាយជាសាធារណៈនូវបញ្ជីឈ្មោះទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត និងការិយាល័យបោះឆ្នោតនៅសាលាឃុំ សង្កាត់ និងនៅទីតាំងមួយចំនួនក្នុងឃុំ សង្កាត់ យ៉ាងយូរនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨។
- កបឃ.ស និងប្រធាន ក.ច.ប ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈអំពីរយៈពេលកាលបរិច្ឆេទ និងប្រតិទិននៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់របស់ខ្លួន ក្នុងរយៈពេលយ៉ាងតិច ៣ថ្ងៃ មុនពេលចាប់ផ្តើមពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត។

### ៣. ការបិទផ្សាយបញ្ជីបោះឆ្នោតចុងក្រោយ

បញ្ជីបោះឆ្នោត ឆ្នាំ២០១៧ ដែល គ.ជ.ប ផ្តល់សុពលភាពចុងក្រោយ ត្រូវបិទផ្សាយយ៉ាងតិច ១០ថ្ងៃ មុនពេលចាប់ផ្តើមការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៨ (បិទផ្សាយនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨)។ បញ្ជីបោះឆ្នោតចុងក្រោយត្រូវប្រើប្រាស់ដូចខាងក្រោម ៖

*បញ្ជីបោះឆ្នោតចុងក្រោយ ចំនួន ៣ច្បាប់*
- *១ច្បាប់ បិទផ្សាយជាសាធារណៈ នៅសាលាឃុំ សង្កាត់ នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨*
- *១ច្បាប់ បិទផ្សាយនៅតាមទីប្រជុំជនក្នុងឃុំ សង្កាត់*
- *១ច្បាប់ សម្រាប់ ក.ច.ប ប្រើប្រាស់។*

### ៤. គំនូសតាងស្តីពីរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត

ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៨ មានរយៈពេល ១៨ថ្ងៃ តាមគំនូសតាងដូចខាងក្រោម៖

| រយៈពេល ៥ថ្ងៃ នៅសាលាឃុំ សង្កាត់ | រយៈពេល ៩ថ្ងៃ នៅតាមភូមិមួយចំនួន | រយៈពេល ៤ថ្ងៃ នៅសាលាឃុំ សង្កាត់ |
|---|---|---|
| ថ្ងៃទី០១ ដល់ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៨ | ថ្ងៃទី០៦ ខែតុលា ដល់ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៨ | ថ្ងៃទី១៥ ខែតុលា ដល់ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៨ |

**ចំណាំ៖**

☛ *ថ្ងៃទី០៨ ដល់ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៨ ឈប់សម្រាកបុណ្យភ្ជុំបិណ្ឌ។*

### ៥. ការទទួលខុសត្រូវលើការងារសន្តិសុខសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត

កបឃ.ស ត្រូវចាត់ចែងតាមលទ្ធភាព និងការចាំបាច់ឱ្យមានកម្លាំងរក្សាសណ្តាប់ធ្នាប់ដែលមានភារកិច្ចដូចខាងក្រោម៖

- សម្រួលសណ្តាប់ធ្នាប់សម្រាប់ប្រជាពលរដ្ឋ ដែលចូលមកកាន់ការិយាល័យចុះឈ្មោះបោះឆ្នោត ដើម្បីសុំចុះឈ្មោះបោះឆ្នោត
- សម្រួលអនុញ្ញាតឱ្យចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោតម្តង ៣នាក់
- ផ្តល់អាទិភាពចំពោះព្រះសង្ឃ ជនចាស់ជរា ស្ត្រីមានផ្ទៃពោះ ស្ត្រីមានកូនតូច អ្នកមានជំងឺ និងជនដែលមានពិការភាព ចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត
- អនុញ្ញាតឱ្យអ្នកជំនួយជានីតិជនម្នាក់ ជូនដំណើរជនដែលមានពិការភាពដែលមិនអាចចុះឈ្មោះបោះឆ្នោតដោយខ្លួនឯងបាន ចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត
- រាយការណ៍ជាបន្ទាន់ជូន កបឃ.ស ក្នុងករណីមានការអុកឡុករំខានពីជនណាម្នាក់ ឬច្រើននាក់ ដើម្បីមានវិធានការស្នើសុំអន្តរាគមន៍ពីភ្នាក់ងារសន្តិសុខ ឬ/និងអាជ្ញាធរមានសមត្ថកិច្ច។

## II. សម្ភារសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត

### ១. សម្ភារបរិក្ខារកុំព្យូទ័របម្រើឱ្យការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៨

សម្ភារ បរិក្ខារកុំព្យូទ័រ សម្រាប់បម្រើការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៨ តាមប្រព័ន្ធកុំព្យូទ័រ រួមមាន៖

| ល-រ | រូបភាព | ចំនួន | ឈ្មោះសម្ភារ | ការប្រើប្រាស់ |
|---|---|---|---|---|
| 1 |  | 1 | កុំព្យូទ័រយួរដៃ | សម្រាប់បញ្ចូល កែតម្រូវ លុប ផ្ទេរទិន្នន័យអ្នកចុះឈ្មោះបោះឆ្នោត |
| 2 |  | 1 | Power Bank | ឧបករណ៍ផ្ទុកថាមពល សម្រាប់ជំនួយរាល់កុំព្យូទ័រ ករណីគ្មានបណ្តាញអគ្គិសនី |
| 3 |  | 1 | Mouse | ឧបករណ៍បញ្ជាកុំព្យូទ័រ |
| 4 |  | 1 | ម៉ូនីទ័រកុំព្យូទ័រទី២ | បង្ហាញទិន្នន័យអ្នកចុះឈ្មោះ កែតម្រូវ និងផ្ទេរទិន្នន័យ |
| 5 |  | 1 | ម៉ាស៊ីនផ្តិតស្នាមម្រាមដៃ | ផ្តិតស្នាមម្រាមដៃ |
| 6 |  | 1 | កាមេរ៉ាថតរូបភាព | ថតរូបអ្នកសុំចុះឈ្មោះ និងឯកសារភ្ជាប់ |

| | | | | |
|---|---|---|---|---|
| 7 |  | 1 | Scanner | ទ្រកាមេរ៉ា និងសម្រាប់ស្កែនអត្តសញ្ញាណប័ណ្ណ... |
| 8 |  | 1 | Modem | ភ្ជាប់ប្រព័ន្ធអ៊ីនធឺណេតតាមរយៈស៊ីមកាត |
| 9 |  | 1 | USB HUB | ជាឧបករណ៍សម្រាប់បំបែករន្ធ USB ឱ្យបានច្រើន |
| 9 |  | 1 | USB Flash | ផ្ទុកទិន្នន័យអ្នកចុះឈ្មោះបោះឆ្នោត |
| 10 |  | 1 | USB Extend | សម្រាប់ភ្ជាប់ពីកុំព្យូទ័រទៅ Modem |
| 11 |  | 1 | SD Card | ផ្ទុកទិន្នន័យអ្នកចុះឈ្មោះបោះឆ្នោតរក្សាទុក |
| 12 |  | 1 | ផ្ទាំងកំណាត់ប្រផេះ | ផ្ទៃក្រោយសម្រាប់ថតរូប |
| 13 |  | 1 | ព្រីភ្លើង | ភ្ជាប់ចរន្តអគ្គិសនីចូលកុំព្យូទ័រ |
| 14 |  | 1 | ម៉ាស៊ីនភ្លើង | ផ្គត់ផ្គង់ថាមពលអគ្គិសនី (តំបន់គ្មានថាមពលអគ្គិសនី) |
| 15 |  | 1 | ខ្សែ Network | ភ្ជាប់ប្រព័ន្ធ Network (កុំព្យូទ័រ២ - ៣គ្រឿង) |
| 16 |  | 1 | Switch | ភ្ជាប់ប្រព័ន្ធ Network (កុំព្យូទ័រ២គ្រឿង) |
| 17 |  | 1 | កាបូបស្ពាយ | ដាក់កុំព្យូទ័រយួរដៃ និងបរិក្ខារកុំព្យូទ័រ |
| 18 |  | 1 | កេសអាលុយមីញ៉ូម | ដាក់សម្ភារបរិក្ខារកុំព្យូទ័រ |

២. របៀបប្រើប្រាស់ក្តារចុច Unicode Standard សម្រាប់ Window7




៣. របៀបរក្សាទុកសម្ភារ បរិក្ខារកុំព្យូទ័រ

បន្ទាប់ពីការចុះឈ្មោះបោះឆ្នោតប្រចាំថ្ងៃរួចហើយ យើងត្រូវរៀបចំទុកដាក់សម្ភារ បរិក្ខារកុំព្យូទ័រទាំងអស់ដាក់ចូលកេស និងរក្សាទុកឱ្យបានត្រឹមត្រូវ ដូចខាងក្រោម ៖

- សម្ភារដែលងាយនឹងបាក់បែក ដូចជាកុំព្យូទ័រយួរដៃ អេក្រង់កុំព្យូទ័រទី២ កាមេរ៉ា ម៉ាស៊ីនផ្តិតស្នាមម្រាមដៃ ត្រូវដាក់ចូលក្នុងកាតាប។

- សម្ភារណាដែលតូចៗ និងងាយបាត់ ដូចជា USB Flash, Modem, Sim card, SD card, Mouse,...ត្រូវដាក់ចូលក្នុងកាបូប ឬកាតាប។
- សម្ភារណាធ្ងន់ៗត្រូវដាក់នៅខាងក្រោមរីឯសម្ភារណាស្រាលៗត្រូវដាក់នៅពីលើ។
- ត្រូវយកកុំព្យូទ័រយួរដៃ និង Power Bank ទៅសាកថ្មឱ្យបានពេញនៅពេលចប់ការចុះឈ្មោះបោះឆ្នោតប្រចាំថ្ងៃនៅពេលល្ងាច ដើម្បីឱ្យមានថាមពលអគ្គិសនីពេញសម្រាប់បន្តការចុះឈ្មោះបោះឆ្នោតនៅថ្ងៃស្អែកទៀត សម្រាប់ឃុំ សង្កាត់ណាដែលពុំមានថាមពលអគ្គិសនីគ្រប់គ្រាន់។
- រៀបចំទុកដាក់សម្ភារចុះឈ្មោះបោះឆ្នោតទាំងអស់ចូលទៅក្នុងកេសស័ង្កសី រួចចាក់សោ និងរក្សាទុកនៅកន្លែងណាដែលមានសីតុណ្ហភាពត្រជាក់ល្មម ស្ងួត និងមានសុវត្ថិភាព។

## III. តួនាទី និងភារកិច្ចរបស់ ក.ច.ប

### ១. តួនាទី និងភារកិច្ចរបស់ ក.ច.ប

កម្មវិធីចុះឈ្មោះបោះឆ្នោតនៅតាមឃុំ សង្កាត់មានទម្រង់ប្រើប្រាស់ទៅតាមកម្រិតតួនាទីនិងភារកិច្ចរបស់អ្នកប្រើប្រាស់ម្នាក់ៗ ដែលច្បាប់ បទបញ្ញា និងនីតិវិធីសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ តម្រូវឱ្យទទួលខុសត្រូវរៀងៗខ្លួនទៅតាមទម្រង់ប្រើប្រាស់ដូចខាងក្រោម ៖

- **ប្រធានក្រុមចុះឈ្មោះបោះឆ្នោត** មានតួនាទីជាអ្នកផ្តល់សិទ្ធិដល់ជនពិការដៃ ឬជនដែលខូចស្នាមខ្មៅដៃ (User អក្សរ L)
- **ការីកាន់ម៉ាស៊ីនមេ** មានតួនាទីជាការីចុះឈ្មោះបោះឆ្នោត និងមានសិទ្ធិក្នុងការបញ្ជូនទិន្នន័យមក ន.គ្រប់គ្រងទិន្នន័យ និងផ្តល់សិទ្ធិរួមគ្នាជាមួយប្រធានក្រុមក្នុងការលុបឈ្មោះអ្នកបោះឆ្នោតចេញពីបញ្ជីបោះឆ្នោត (User អក្សរ T)
- **ការីកុំព្យូទ័រចុះឈ្មោះបោះឆ្នោត** (*ករណីមានម៉ាស៊ីនចាប់ពី ២គ្រឿងឡើងទៅ*) មានតួនាទីជាការីចុះឈ្មោះបោះឆ្នោត និងផ្តល់សិទ្ធិរួមគ្នាជាមួយប្រធានក្រុមក្នុងការលុបឈ្មោះអ្នកបោះឆ្នោតចេញពីបញ្ជីបោះឆ្នោត (User អក្សរ R)។

### ២. ប្រព័ន្ធសុវត្ថិភាព និងរបៀបផ្លាស់ប្តូរលេខសម្ងាត់ (Security Login)

ដើម្បីអាចប្រើប្រាស់កម្មវិធីនេះ តម្រូវឱ្យមានការត្រួតពិនិត្យលើប្រព័ន្ធសុវត្ថិភាព (Security login) ជាមុនសិន ទើបអនុញ្ញាតប្រើប្រាស់បាន។ អ្នកប្រើប្រាស់ត្រូវវាយបញ្ចូលអត្តលេខ និងលេខសម្ងាត់ដែលយើងបានផ្លាស់ប្តូររួច ឬផ្តិតស្នាមម្រាមដៃអ្នកប្រើប្រាស់ម្នាក់ៗទៅតាមកម្រិតប្រើប្រាស់របស់ខ្លួន(ប្រធាន ក.ច.ប ឬការីកាន់ម៉ាស៊ីនមេ ឬការីកុំព្យូទ័រ)។

**របៀប Login ប្រព័ន្ធសុវត្ថិភាព**

ដើម្បី Login ចូលប្រព័ន្ធសុវត្ថិភាពត្រូវអនុវត្តដូចខាងក្រោម៖

- បញ្ចូលអត្តលេខដែល **គ.ជ.ប** បានផ្តល់ជូន ឧ: COM12037T001
- បញ្ចូលលេខសម្ងាត់ ដែល **គ.ជ.ប** បានផ្តល់ជូន ឧ: Pil0t_@2o15
- ចុចលើប៊ូតុង <u>ឡុកចូលប្រព័ន្ធ</u> ឬចុច <u>Enter</u>
- ឬ Login ចូលប្រព័ន្ធសុវត្ថិភាពតាមរយៈផ្តិត<u>ស្នាមម្រាមដៃ</u>។ មើលរូបខាងក្រោម ៖




(រូបភាពទី១)




(រូបភាពទី២)

៣. របៀបផ្លាស់ប្តូរលេខសម្ងាត់ និងបញ្ចូលស្នាមម្រាមដៃ

នៅពេលដែលយើង Login ចូលប្រព័ន្ធសុវត្ថិភាពរួច កម្មវិធីនេះ តម្រូវឱ្យអ្នកប្រើប្រាស់ ដាច់ខាតត្រូវតែធ្វើការផ្លាស់ប្តូរលេខសម្ងាត់សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួនជាមុនសិន។ ប្រសិនបើយើងមិនបានផ្លាស់ប្តូរលេខសម្ងាត់នោះទេ កម្មវិធីនេះមិនអាចដំណើរការបានទេ ហើយវានឹងបង្ហាញសារមួយ ដូចខាងក្រោម ៖

➢ រួចចុចលើពាក្យថា យល់ព្រម




(រូបភាពទី៣)

បន្ទាប់ពីយើងចុចលើពាក្យថា <u>**យល់ព្រម**</u> ហើយយើងនឹងឃើញផ្ទាំងរូបភាពមួយដែលសរសេរថា ទម្រង់ផ្លាស់ប្តូរលេខសម្ងាត់ ដូចរូបទី៦ ខាងក្រោម ៖

- ចុចលើពាក្យថា **ឯកសារ** → ចុចលើ **អ្នកប្រើប្រាស់** → រួចជ្រើសយកពាក្យ **ផ្លាស់ប្តូរលេខសម្ងាត់** ។
  - បញ្ចូលលេខសម្ងាត់ចាស់ដែល គ.ជ.ប បានផ្តល់ជូន ឧ: Pil0t_@2o15
  - បញ្ចូលលេខសម្ងាត់ថ្មីដោយខ្លួនឯង (ត្រូវបញ្ចូលឱ្យបាន ៨អក្សរយ៉ាងតិច) ឧ: necc_@$1
  - បញ្ជាក់លេខសម្ងាត់ថ្មីម្តងទៀត ឧ: necc_@$1
  - ធីកលើប្រអប់ផ្តិតស្នាមម្រាមដៃ
  - ផ្តិតស្នាមម្រាមដៃដែលអ្នកចង់ប្រើប្រាស់ផ្ទាល់ខ្លួន (ឧ:ផ្តិតមេដៃស្តាំ ៤ដង)
  - រួចចុចលើប៊ូតុង **រក្សាទុក** សូមមើលរូបទី៤ ៥ ៦ និង៧ ដូចខាងក្រោម៖




(រូបភាពទី៤)




(រូបភាពទី៥)




(រូបភាពទី៦)

បន្ទាប់ពីចុចលើប៊ូតុង **រក្សាទុក** រួចហើយយើងនឹងឃើញផ្ទាំងមួយដែលសរសេរថា « លេខសម្ងាត់ផ្លាស់ប្តូរបានដោយជោគជ័យ!! » រួចចុចលើប៊ូតុង **យល់ព្រម** ដើម្បីធ្វើបច្ចុប្បន្នភាពលើលេខសម្ងាត់ ។




(រូបភាពទី៧)

## ៤. របៀប Login ប្រព័ន្ធសុវត្ថិភាពតាមរយៈផ្តិតស្នាមម្រាមដៃ

ក្នុងការ Login ចូលប្រព័ន្ធសុវត្ថិភាពតាមរយៈផ្តិតស្នាមម្រាមដៃនេះ កម្មវិធីមិនតម្រូវឱ្យបញ្ចូល **អត្តលេខ** និង**លេខសម្ងាត់** ក៏បានដែរ ដោយគ្រាន់តែយើងផ្តិតស្នាមម្រាមដៃលើម៉ាស៊ីនផ្តិតស្នាមម្រាមដៃដោយផ្ទាល់តែម្តង។ ដើម្បី Login ចូលប្រព័ន្ធសុវត្ថិភាពតាមរយៈផ្តិតស្នាមម្រាមដៃយើងត្រូវអនុវត្តដូចខាងក្រោម ៖

ជាដំបូងអ្នកប្រើប្រាស់ ត្រូវជូតសម្អាតស្នាមម្រាមដៃជាមុនសិន មុននឹងធ្វើការផ្តិតស្នាមម្រាមដៃ

- មុននឹងយើងផ្តិតស្នាមម្រាមដៃលើម៉ាស៊ីនផ្តិតស្នាមម្រាមដៃ សូមមើលលើម៉ាស៊ីនជាមុនសិនថា វាមានភ្លើងពណ៌ខៀវហើយ ឬនៅ។ ប្រសិនបើម៉ាស៊ីនមានភ្លើងពណ៌ខៀវទើបយើងអាចផ្តិតស្នាមម្រាមដៃបាន។

- ផ្តិតស្នាមម្រាមដៃលើម៉ាស៊ីន រហូតដល់ម៉ាស៊ីនរលត់ភ្លើងពណ៌ខៀវ រួចដកម្រាមដៃចេញ។
- ប្រសិនបើកម្មវិធីមិនទាន់ដំណើរការទេ សូមព្យាយាមផ្តិតម្តងទៀតនៅពេលដែលម៉ាស៊ីនបង្ហាញភ្លើងពណ៌ខៀវមកវិញ។ សូមមើលរូបភាពដូចខាងក្រោម៖




(រូបភាពទី៨)

## IV. ភាពមានសិទ្ធិចុះឈ្មោះបោះឆ្នោត

### ១. លក្ខខណ្ឌដើម្បីមានសិទ្ធិចុះឈ្មោះបោះឆ្នោត

ដើម្បីចុះឈ្មោះបោះឆ្នោត ប្រជាពលរដ្ឋទាំងពីរភេទត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- ត្រូវបង្ហាញខ្លួន និងមាន អ.ខ ឬឯ.អ នៅចំពោះមុខ ក.ច.ប ដែលទទួលបន្ទុកជាមន្ត្រីចុះឈ្មោះបោះឆ្នោត ក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត នៅការិយាល័យចុះឈ្មោះបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ដែលខ្លួនត្រូវចុះឈ្មោះបោះឆ្នោត
- មានសញ្ជាតិខ្មែរ
- មានអាយុចាប់ពី ១៨ឆ្នាំឡើងទៅ គិតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨
- មានលំនៅឋានឬទីសំណាក់ក្នុងឃុំ សង្កាត់ដែលសាមីខ្លួនត្រូវចុះឈ្មោះបោះឆ្នោត
- មិនទាន់បានចុះឈ្មោះ ឬបានចុះឈ្មោះបោះឆ្នោតនៅឃុំ សង្កាត់ផ្សេងណាមួយរួចហើយ ឬមិនទាន់បានចុះឈ្មោះនៅកន្លែងណាមួយក្នុងឃុំ សង្កាត់។

## ២. ឯកសារសម្រាប់ប្រើប្រាស់ក្នុងការសុំចុះឈ្មោះបោះឆ្នោត

ឯកសារសម្រាប់ប្រើប្រាស់ក្នុងការសុំចុះឈ្មោះបោះឆ្នោត គឺអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (អ.ខ) ទាំង ៣ប្រភេទ ដូចខាងក្រោម ៖

# អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ

ប្រភេទទី១




ឬ

ប្រភេទទី២




ឬ

ប្រភេទទី៣




## V. ដំណើរប្រព្រឹត្តទៅនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត

### ១. ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៨

ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៨ ចាប់ផ្តើមពីថ្ងៃទី១ ដល់ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៨ នៅតាមសាលាឃុំ សង្កាត់ និងនៅតាមភូមិមួយចំនួនក្នុងឃុំ សង្កាត់ទូទាំងប្រទេស។

ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៨ មានគោលដៅធានាឱ្យបញ្ជីបោះឆ្នោតមានភាពពេញលេញ ភាពត្រឹមត្រូវ និងមានបច្ចុប្បន្នភាពប្រកបដោយសុវត្ថិភាពតាមរយៈ ៖

❖ ការស្រង់ និងលុបឈ្មោះអ្នកបោះឆ្នោតដែល ៖

- បានទទួលមរណភាព
- ត្រូវបានដកហូតសិទ្ធិបោះឆ្នោតជាបណ្ដោះអាសន្ន
- បានផ្លាស់លំនៅឋាន ឬទីសំណាក់ចេញទៅឃុំ សង្កាត់ផ្សេង

ដោយមានឯកសារជាសំអាងត្រឹមត្រូវ និងច្បាស់លាស់ ដើម្បីលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត។

❖ ការកែតម្រូវឈ្មោះ ឬទិន្នន័យអ្នកបោះឆ្នោត តាមសំណើរបស់សាមីខ្លួនដោយផ្អែកលើឯកសារសំអាងត្រឹមត្រូវ។

❖ ការចុះឈ្មោះអ្នកបោះឆ្នោត

ការចុះឈ្មោះអ្នកបោះឆ្នោត សំដៅលើ៖

- ប្រជាពលរដ្ឋខ្មែរមានសិទ្ធិបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលមិនទាន់បានចុះឈ្មោះបោះឆ្នោត
- ប្រជាពលរដ្ឋខ្មែរដែលទើបគ្រប់អាយុ ១៨ឆ្នាំឡើង គិតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨
- ប្រជាពលរដ្ឋខ្មែរដែលបានផ្លាស់លំនៅឋាន ឬទីសំណាក់ចូលឃុំ សង្កាត់ថ្មី ត្រូវទៅចុះឈ្មោះបោះឆ្នោតនៅតាមសាលាឃុំ សង្កាត់ដែល សាមីខ្លួនត្រូវចុះឈ្មោះបោះឆ្នោត។

ការចុះឈ្មោះបោះឆ្នោត ការកែតម្រូវឈ្មោះ ឬ/និងទិន្នន័យ និងការលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ត្រូវធ្វើតាមប្រព័ន្ធកុំព្យូទ័រ នៅតាមសាលាឃុំ សង្កាត់ ឬនៅតាមភូមិមួយចំនួន ក្នុងឃុំ សង្កាត់នីមួយៗ ចាប់ពីថ្ងៃទី០១ ដល់ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៨។

## ២. ជំហានទាំង ៤ នៃការចុះឈ្មោះបោះឆ្នោត

គ.ជ.ប ត្រូវអនុវត្តការចុះឈ្មោះបោះឆ្នោតតាមនីតិវិធី ដូចបញ្ជាក់ក្នុងជំហានទាំង៤ ដូចខាងក្រោម៖

- ជំហានទី១

ប្រធាន គ.ច.ប ត្រូវ៖

- ធ្វើសម្ភាសន៍អ្នកសុំចុះឈ្មោះបោះឆ្នោត
- សាកសួរព័ត៌មានគាត់ថា៖
  - តើអ្នកមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (អ.ខ) ឬឯកសារបញ្ជាក់អត្តសញ្ញាណ (ឯ.អ) ឬទេ?
  - តើអ្នកបានចុះឈ្មោះបោះឆ្នោតហើយ ឬនៅ?

- ជំហានទី២

ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតមាន អ.ខ ឬ ឯ.អ និងមិនទាន់បានចុះឈ្មោះបោះឆ្នោត ប្រធាន គ.ច.ប ត្រូវ៖

- ពិនិត្យភាពមានសិទ្ធិចុះឈ្មោះបោះឆ្នោតរបស់អ្នកសុំចុះឈ្មោះ ដូចខាងក្រោម៖
  - ផ្ទៀងផ្ទាត់ អ.ខ ឬ ឯ.អ
  - មានអាយុ ១៨ ឆ្នាំ ឡើងទៅគិតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨
  - មានលំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់ដែលសាមីខ្លួនត្រូវបោះឆ្នោត
- ជម្រាបអ្នកសុំចុះឈ្មោះឱ្យទៅជួបអនុប្រធាន គ.ច.ប ដើម្បីបន្តនីតិវិធីចុះឈ្មោះបោះឆ្នោតតាមជំហានបន្តបន្ទាប់ (ក្នុងករណីអ្នកសុំចុះឈ្មោះបោះឆ្នោតបានបំពេញគ្រប់លក្ខខណ្ឌកំណត់)។

ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតពុំមាន អ.ខ ឬមាន អ.ខ ប៉ុន្តែពុំមានលក្ខខណ្ឌគ្រប់គ្រាន់ ប្រធាន គ.ច.ប ត្រូវ៖

បដិសេធការសុំចុះឈ្មោះ ដោយទម្រង់បែបបទបដិសេធការសុំចុះឈ្មោះបោះឆ្នោត (ទ.១០០៩) ដោយបញ្ជាក់ពីមូលហេតុ និងលក្ខខណ្ឌដែលអ្នកសុំចុះឈ្មោះបោះឆ្នោតមិនបានបំពេញ។

- ជំហានទី៣

ករណីអ្នកស្នើសុំចុះឈ្មោះបោះឆ្នោតមានលក្ខខណ្ឌគ្រប់គ្រាន់ដើម្បីសុំចុះឈ្មោះបោះឆ្នោត អនុប្រធាន គ.ច.ប ត្រូវ ៖

- សួរទីលំនៅ នៅភូមិណា ដើម្បីកំណត់បញ្ចូលឈ្មោះក្នុងការិយាល័យបោះឆ្នោតក្នុងភូមិនោះ
- បំពេញទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២ មានអត្តលេខ)ដោយផ្អែកតាមទិន្នន័យក្នុង អ.ខ ឬ ឯ.អ ចុះហត្ថលេខាសរសេរឈ្មោះ បោះត្រា និងបោះត្រាបន្ថែមនៅលើ ទ.១០២២ រវាងគល់ទម្រង់ និងបង្កាន់ដៃ
- ប្រគល់ អ.ខ ឬ ឯ.អ ឬឯកសារបញ្ជាក់ពីលំនៅឋាន ឬទីសំណាក់ និងបង្កាន់ដៃ ទ.១០២២ ទៅការីកុំព្យូទ័រ និងជម្រាបអ្នកសុំចុះឈ្មោះនោះឱ្យទៅជួបការីកុំព្យូទ័រ។

- **ជំហានទី៤**

ការីកុំព្យូទ័រត្រូវ៖

*បញ្ចូលទិន្នន័យអ្នកសុំចុះឈ្មោះបោះឆ្នោតទៅក្នុងប្រព័ន្ធកុំព្យូទ័រដោយផ្អែកតាម អ.ខ ឬ ឯ.អ និងបង្កាន់ដៃ ទ.១០២២ ដូចខាងក្រោម ៖*

- *ជ្រើសយកឈ្មោះទីតាំង និងលេខកូដការិយាល័យបោះឆ្នោតទៅតាមភូមិអ្នកសុំចុះឈ្មោះ*
- *ជូតសម្អាតមេដៃអ្នកសុំចុះឈ្មោះបោះឆ្នោតជាមុន បន្ទាប់មកធ្វើតេស្តស្នាមមេដៃទាំងសងខាង។ ចំពោះអ្នកពិការដៃម្ខាង ឬទាំងសងខាង ឬគ្មានស្នាមម្រាមដៃ ប្រធាន ក.ច.ប ត្រូវផ្តល់សិទ្ធិសម្រាប់ដំណើរការកម្មវិធី*
- *ថត អ.ខ ឬ ឯ.អ*
- *ជ្រើសរើសប្រវត្តិចុះឈ្មោះបោះឆ្នោត (មិនទាន់បានចុះឈ្មោះបោះឆ្នោត ឬបានចុះឈ្មោះ ឆ្នាំ២០១៨)*
- *ជ្រើសរើសយកប្រភេទឯកសារសម្រាប់ប្រើចុះឈ្មោះបោះឆ្នោត (អ.ខ ឬ ឯ.អ)*
- *បញ្ចូលលេខ អ.ខ ឬ ឯ.អ*
- *បញ្ចូលអត្តលេខ អ្នកសុំចុះឈ្មោះដែលមាននៅក្នុងបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត*
- *បញ្ចូលនាមត្រកូល នាមខ្លួន ភេទ ថ្ងៃ ខែ ឆ្នាំកំណើត*
- *បញ្ចូលលំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់របស់សាមីខ្លួន*
- *ថតរូបចំពីមុខ*
- *ជ្រើសរើសភូមិឧបសម្ព័ន្ធ (ប្រសិនបើមាន)*
- *ជ្រើសរើសស្ថានភាពពិការភាពរបស់អ្នកសុំចុះឈ្មោះបោះឆ្នោត(ប្រសិនបើមាន)*
- *ថតរូបអ្នកសុំចុះឈ្មោះបោះឆ្នោតចំពីមុខ*
- *ជួយកាន់មេដៃអ្នកសុំចុះឈ្មោះបោះឆ្នោតដាក់លើម៉ាស៊ីនស្កេន ដើម្បីយកស្នាមមេដៃសាមីខ្លួនទាំងសងខាងឆ្វេងចំនួន ៤ដង និងស្តាំចំនួន ៤ដង បញ្ចូលទៅក្នុងប្រព័ន្ធកុំព្យូទ័រ ដោយត្រូវយកស្នាមមេដៃឆ្វេងមុន។ ក្នុងករណីអ្នកសុំចុះឈ្មោះពិការមេដៃណាមួយ ឬទាំងសងខាង ត្រូវយកស្នាមម្រាមដៃបន្តបន្ទាប់ជំនួស ហើយក្នុងករណីអ្នកសុំចុះឈ្មោះពិការដៃម្ខាង ត្រូវយកស្នាមមេដៃម្ខាងដែលមាន។ ចំពោះអ្នកសុំចុះឈ្មោះដែលមិនអាចផ្តល់ស្នាមម្រាមដៃបាន ត្រូវកត់ត្រាចូលក្នុងរបាយការណ៍ជូន គ.ជ.ប*
- *ថតឯកសារបញ្ជាក់ពីលំនៅឋាន ឬទីសំណាក់(ប្រសិនបើមាន)។ ក្នុងការថតឯកសារបញ្ជាក់ពីលំនៅឋានឬទីសំណាក់ការីកុំព្យូទ័រត្រូវថតយកដូចខាងក្រោម៖*
    - *ថតយកសន្លឹកទី២ ដែលបញ្ជាក់ពីលំនៅឋាន សម្រាប់សៀវភៅគ្រួសារ*
    - *ថតយកសន្លឹកទី១ ដែលបញ្ជាក់ពីលំនៅឋាន សម្រាប់សៀវភៅស្នាក់នៅ*
    - *ថតយកទម្រង់ទាំងមូល សម្រាប់លិខិតបញ្ជាក់ទីលំនៅ*
- *ជម្រាបអ្នកសុំចុះឈ្មោះបោះឆ្នោតឱ្យគាត់ផ្ទៀតផ្ទាត់ឈ្មោះ និងទិន្នន័យរបស់ខ្លួនដែលបានបង្ហាញនៅលើម៉ូនីទ័រកុំព្យូទ័រ។ ករណីអ្នកសុំចុះឈ្មោះមិនចេះអក្សរ ឬមើលមិនច្បាស់ គាត់អាចស្នើសុំជំនួយពីអ្នកដទៃបាន ដើម្បីផ្ទៀងផ្ទាត់ទិន្នន័យរបស់គាត់។*
- *រក្សាទុកទិន្នន័យអ្នកសុំចុះឈ្មោះបោះឆ្នោតទៅក្នុងប្រព័ន្ធកុំព្យូទ័រ។ ចំពោះអ្នកសុំចុះឈ្មោះដែលមិនអាចផ្តល់ស្នាមម្រាមដៃបាន ប្រធាន ក.ច.ប ត្រូវផ្តល់សិទ្ធិសម្រាប់រក្សាទុកទិន្នន័យអ្នកសុំចុះឈ្មោះបោះឆ្នោតទៅក្នុងប្រព័ន្ធកុំព្យូទ័រ។*
- *ប្រគល់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត និង អ.ខ ឬ ឯ.អ ឬឯកសារបញ្ជាក់ពីលំនៅឋាន ឬទីសំណាក់ ជូនអ្នកសុំចុះឈ្មោះបោះឆ្នោត។*

### ៣. ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត តាមករណីនីមួយៗ

ការចុះឈ្មោះបោះឆ្នោត ការកែតម្រូវឈ្មោះ ឬ/និងទិន្នន័យ ការប្ដូរការិយាល័យបោះឆ្នោត ការលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតនៅតាមឃុំ សង្កាត់ ក.ច.ប ត្រូវអនុវត្តតាមករណីនីមួយៗជាក់ស្ដែង ដូចខាងក្រោម ៖

**ក. ករណី ពុំមាន អ.ខ ឬមាន អ.ខ ប៉ុន្តែពុំមានលក្ខខណ្ឌគ្រប់គ្រាន់**

នៅពេលអ្នកសុំចុះឈ្មោះបោះឆ្នោតបានមកជួបប្រធាន ក.ច.ប ប្រធានត្រូវអនុវត្តជំហានទី១ និងទី២ បន្ទាប់ពីអនុវត្តជំហានទាំង២ហើយ ប្រសិនបើ ៖

- **ក្នុងករណីអ្នកសុំចុះឈ្មោះបោះឆ្នោតពុំមាន អ.ខ**
  - ប្រធានត្រូវបដិសេធការសុំចុះឈ្មោះបោះឆ្នោត (ទ.១០០៩) ដោយបញ្ជាក់ និងជម្រាបពីមូលហេតុ និងលក្ខខណ្ឌដែលអ្នកសុំចុះឈ្មោះបោះឆ្នោតមិនបានបំពេញ និងណែនាំគាត់ដូចខាងក្រោម ៖
    - ជម្រាបអ្នកសុំចុះឈ្មោះ ឱ្យទៅរាយការណ៍ជាបន្ទាន់ជូនអាជ្ញាធរមានសមត្ថកិច្ច ដើម្បីបំពេញបែបបទផ្ដល់ អ.ខ ជូន ហើយទន្ទឹមនឹងនេះ
    - ជម្រាបអ្នកសុំចុះឈ្មោះឱ្យទៅស្នើសុំ ឯ.អ ពីអាជ្ញាធរឃុំ សង្កាត់
  - ជម្រាបអ្នកសុំចុះឈ្មោះបោះឆ្នោតថា នៅពេលអ្នកទទួលបាន អ.ខ ឬ ឯ.អ អ្នកត្រូវត្រឡប់មកជួប ក.ច.ប វិញ ដើម្បីសុំចុះឈ្មោះបោះឆ្នោត។
- **ក្នុងករណីអ្នកសុំចុះឈ្មោះ មាន អ.ខ ប៉ុន្តែអាសយដ្ឋានក្នុង អ.ខ ផ្សេងពីលំនៅឋាន ឬទីសំណាក់**
  - ប្រធានត្រូវបដិសេធការសុំចុះឈ្មោះបោះឆ្នោត (ទ.១០០៩) ដោយបញ្ជាក់ និងជម្រាបពីមូលហេតុ និងលក្ខខណ្ឌដែលអ្នកសុំចុះឈ្មោះបោះឆ្នោតមិនបានបំពេញ និងណែនាំគាត់ ដូចខាងក្រោម ៖
    - ជម្រាបអ្នកសុំចុះឈ្មោះបោះឆ្នោត ឱ្យទៅយកសៀវភៅស្នាក់នៅច្បាប់ដើម ឬសៀវភៅគ្រួសារច្បាប់ដើម ដែលមានបញ្ជាក់ពីការស្នាក់នៅរបស់សាមីខ្លួនក្នុងឃុំ សង្កាត់ដែលត្រូវសុំចុះឈ្មោះបោះឆ្នោត
    - បើគាត់ពុំមានសៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារច្បាប់ដើមទេ គាត់ត្រូវទៅស្នើសុំលិខិតបញ្ជាក់ទីលំនៅពីអាជ្ញាធរឃុំ សង្កាត់
  - ជម្រាបអ្នកសុំចុះឈ្មោះបោះឆ្នោត នៅពេលគាត់យកសៀវភៅស្នាក់នៅច្បាប់ដើម ឬសៀវភៅគ្រួសារច្បាប់ដើមបានហើយ ឬទទួលបាន ឯ.អ គាត់ត្រូវត្រឡប់មកជួប ក.ច.ប វិញ ដើម្បីសុំចុះឈ្មោះបោះឆ្នោត។ ការចុះឈ្មោះបោះឆ្នោតក្នុងករណីនេះ ត្រូវអនុវត្តនីតិវិធី ដូចបញ្ជាក់ក្នុងជំហានទាំង៤ ខាងលើ។

**ខ. ករណីអ្នកសុំចុះឈ្មោះបោះឆ្នោត បានចុះឈ្មោះបោះឆ្នោតរួចហើយ ប៉ុន្តែឈ្មោះ ឬ/និងទិន្នន័យក្នុងបញ្ជីបោះឆ្នោតកត់ត្រាមិនត្រឹមត្រូវ**

❖ **ករណីទី១ អ្នកសុំចុះឈ្មោះបោះឆ្នោត បានចុះឈ្មោះបោះឆ្នោតរួចហើយ ឆ្នាំ២០១៨**

ប្រធាន ក.ច.ប ត្រូវជម្រាបអ្នកសុំកែតម្រូវឱ្យទៅជួបការីកុំព្យូទ័រ ដើម្បីបន្តនីតិវិធីស្វែងរកប្រវត្តិចុះឈ្មោះបោះឆ្នោតរបស់គាត់ ដូចខាងក្រោម ៖

➢ **ករណីទិន្នន័យរបស់អ្នកស្នើសុំពុំទាន់ត្រូវបានបញ្ជូនមក គ.ជ.ប**

- **ករណីទិន្នន័យក្នុងកុំព្យូទ័រត្រឹមត្រូវ តែទិន្នន័យក្នុង ទ.១០២២ ខុស**
  - ☛ ការីកុំព្យូទ័រ ទាញយកទិន្នន័យ តាមរយៈស្នាមម្រាមដៃ ឬតាមលេខ អ.ខ ឬ ឯ.អ របស់អ្នកស្នើសុំ
  - ☛ ចាត់អនុប្រធាន ឱ្យធ្វើការកែតម្រូវទិន្នន័យជូនអ្នកសុំ នៅលើ ទ.១០២២ ទាំងពីរផ្នែកឡើងវិញ ដោយឆូតលើទិន្នន័យក្នុង ទ.១០២២ ដែលខុសទាំងពីរផ្នែកនោះ រួចសរសេរទិន្នន័យដែលត្រឹមត្រូវក្បែរនោះ តាមទិន្នន័យ ក្នុង អ.ខ ឬ ឯ.អ និងចុះហត្ថលេខា បោះត្រា ដើម្បីបញ្ជាក់ថា បានកែតម្រូវឈ្មោះ ឬទិន្នន័យ តាមការស្នើសុំ។
- **ករណីទិន្នន័យក្នុង ទ.១០២២ ត្រឹមត្រូវ តែទិន្នន័យក្នុងកុំព្យូទ័រខុស**
  - ☛ ចាត់ការីកុំព្យូទ័រឱ្យ ៖
    - ○ ទាញយកទិន្នន័យ តាមរយៈស្នាមម្រាមដៃ ឬតាមលេខ អ.ខ ឬ ឯ.អ របស់អ្នកស្នើសុំ
    - ○ កែតម្រូវទិន្នន័យ ដោយផ្អែកលើ អ.ខ ឬឯ.អ របស់អ្នកស្នើសុំ
    - ○ ជម្រាបអ្នកសុំកែតម្រូវឱ្យផ្ទៀងផ្ទាត់ទិន្នន័យរបស់ខ្លួនដែលបង្ហាញនៅលើម៉ូនីទ័រកុំព្យូទ័រ
    - ○ យកស្នាមម្រាមដៃសាមីខ្លួនបញ្ចូលក្នុងប្រព័ន្ធកុំព្យូទ័រ ដើម្បីបញ្ជាក់ថាបានកែតម្រូវត្រឹមត្រូវ និងសម្រាប់រក្សាទុកទិន្នន័យតាមការស្នើសុំ បន្ទាប់មករក្សាទុកទិន្នន័យរបស់អ្នកសុំកែតម្រូវក្នុងប្រព័ន្ធកុំព្យូទ័រ។
- **ករណីទិន្នន័យក្នុង ទ.១០២២ ក៏ខុស ហើយទិន្នន័យក្នុងកុំព្យូទ័រក៏ខុស**
  - ☛ ការីកុំព្យូទ័រ ទាញយកទិន្នន័យ តាមរយៈស្នាមម្រាមដៃ ឬតាមលេខ អ.ខ ឬ ឯ.អ របស់អ្នកស្នើសុំ
  - ☛ អនុប្រធានត្រូវ ៖
    - ○ កែតម្រូវទិន្នន័យជូនអ្នកសុំ នៅលើ ទ.១០២២ ទាំងពីរផ្នែកឡើងវិញ ដោយឆូតលើទិន្នន័យក្នុង ទ.១០២២ ដែលខុសទាំងពីរផ្នែកនោះ

- រួចសរសេរទិន្នន័យដែលត្រឹមត្រូវក្បែរនោះ តាមទិន្នន័យក្នុង អ.ខ ឬ ឯ.អ និងចុះហត្ថលេខា បោះត្រា ដើម្បីបញ្ជាក់ថា បានកែតម្រូវឈ្មោះ ឬទិន្នន័យ តាមការស្នើសុំ។

☛ **ការកែតម្រូវទិន្នន័យក្នុងកុំព្យូទ័រ ត្រូវ៖**

- ធ្វើការកែតម្រូវទិន្នន័យ ដោយផ្អែកលើ អ.ខ ឬឯ.អ របស់អ្នកស្នើសុំ
- ជម្រាបអ្នកសុំកែតម្រូវឱ្យផ្ទៀងផ្ទាត់ទិន្នន័យរបស់ខ្លួនដែលបង្ហាញនៅលើម៉ូនីទ័រកុំព្យូទ័រ
- យកស្នាមម្រាមដៃសាមីខ្លួនបញ្ចូលក្នុងប្រព័ន្ធកុំព្យូទ័រ ដើម្បីបញ្ជាក់ថាបានកែតម្រូវត្រឹមត្រូវ និងសម្រាប់រក្សាទុកទិន្នន័យតាមការស្នើសុំ បន្ទាប់មករក្សាទុកទិន្នន័យរបស់អ្នកសុំកែតម្រូវក្នុងប្រព័ន្ធកុំព្យូទ័រ។

**ចំណាំ ៖** ការកែតម្រូវក្នុងករណីនេះ អាចធ្វើបានលុះត្រាតែទិន្នន័យពុំទាន់បានបញ្ជូនមក ន.គ.ទ.ប។

➢ **ករណីទិន្នន័យរបស់អ្នកស្នើសុំ ត្រូវបាន ក.ច.ប បញ្ជូនមក គ.ជ.ប**

ករណីនេះ អ្នកស្នើសុំកែតម្រូវ អាចសុំផ្ទៀងផ្ទាត់ទិន្នន័យក្នុងប្រព័ន្ធកុំព្យូទ័រជាមួយបង្កាន់ ទ.១០២២ ឬ អ.ខ ឬ ឯ.អ បាន ប៉ុន្តែមិនអាចកែតម្រូវទិន្នន័យបានទេ។ បើទិន្នន័យក្នុងប្រព័ន្ធកុំព្យូទ័រមិនត្រឹមត្រូវ ក.ច.ប ត្រូវណែនាំគាត់ឱ្យរង់ចាំប្ដឹងតវ៉ាសុំកែតម្រូវទិន្នន័យនៅក្នុងអំឡុងពេលនៃការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង។

❖ **ករណីទី២ អ្នកសុំចុះឈ្មោះបោះឆ្នោតបានចុះឈ្មោះរួចហើយ មុនឆ្នាំ២០១៨**

ប្រធាន ក.ច.ប ត្រូវស្នើសុំឱ្យគាត់បង្ហាញ អ.ខ ឬ ឯ.អ ដែលមានទិន្នន័យត្រឹមត្រូវ និងបង្ហាញបង្កាន់ ទ.១០២២ បើមាន។ ប្រសិនបើឯកសារដែលគាត់បង្ហាញត្រឹមត្រូវហើយ ប្រធាន ក.ច.ប ត្រូវចាត់ចែងដូចខាងក្រោម ៖

☛ ចាត់អនុប្រធាន ក.ច.ប ឱ្យបំពេញ ទ.១០២៨ ជូនសាមីអ្នកស្នើសុំ ។

☛ ចាត់ការីកុំព្យូទ័រ ឱ្យអនុវត្តដូចខាងក្រោម ៖

- យកស្នាមមេដៃរបស់អ្នកស្នើសុំកែតម្រូវ ដើម្បីទាញយកទិន្នន័យមកកែតម្រូវ ឬស្វែងរកទិន្នន័យអ្នកស្នើសុំកែតម្រូវតាមរយៈលេខ អ.ខ ឬ អត្តលេខ ឬនាមត្រកូលនាមខ្លួន (ករណីអ្នកស្នើសុំកែតម្រូវ មិនអាចផ្តល់ស្នាមមេដៃបាន)
- កែតម្រូវទិន្នន័យ ដោយផ្អែកលើ អ.ខ ឬ ឯ.អ ដែលត្រឹមត្រូវ
- ជម្រាបអ្នកសុំកែតម្រូវឱ្យផ្ទៀងផ្ទាត់ទិន្នន័យរបស់ខ្លួន ដែលបង្ហាញនៅលើម៉ូនីទ័រកុំព្យូទ័រ

- ស្នើអ្នកសុំកែតម្រូវផ្តល់ស្នាមម្រាមដៃបញ្ចូលក្នុងប្រព័ន្ធកុំព្យូទ័រ ដើម្បីបញ្ជាក់ថា គាត់ពិតជាបានស្នើសុំកែតម្រូវទិន្នន័យ។
- ប្រគល់បង្កាន់ដៃ ទ.១០២៨ ឱ្យអ្នកស្នើសុំកែតម្រូវ ។

**គ. ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតមាន អ.ខ ឬ ឯ.អ និងធ្លាប់បានចុះឈ្មោះបោះឆ្នោតរួចហើយ**

ប្រសិនបើអ្នកសុំចុះឈ្មោះបោះឆ្នោតឆ្លើយថា គាត់ធ្លាប់ចុះឈ្មោះបោះឆ្នោតម្តងរួចហើយ ប្រធាន ក.ច.ប ត្រូវបន្តសំណួរថា តើអ្នកធ្លាប់ចុះឈ្មោះបោះឆ្នោតនៅឃុំ សង្កាត់ណា ឆ្នាំណា ?

❖ **ករណីអ្នកសុំចុះឈ្មោះបោះឆ្នោត បានចុះឈ្មោះបោះឆ្នោតរួចហើយ តែបានប្តូរទីលំនៅក្នុងឃុំ សង្កាត់ដដែល ឬសុំប្តូរការិយាល័យបោះឆ្នោតក្នុងភូមិជាមួយ**

ប្រធាន ក.ច.ប ត្រូវសុំពិនិត្យមើល អ.ខ បង្កាន់ ទ.១០២២ និងឯកសារភ័ស្តុតាងដែលបញ្ជាក់ទីលំនៅថ្មី នៅក្នុងឃុំ សង្កាត់ ដូចជាសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ឬលិខិតបញ្ជាក់ទីលំនៅរួចហើយ ប្រធាន ត្រូវ ៖

- **ចាត់អនុប្រធានឱ្យ ៖**
  - បំពេញទម្រង់បង្កាន់ដៃ ទ.១០២៨
  - ឱ្យអ្នកស្នើសុំផ្តិតមេដៃ និងសរសេរឈ្មោះលើ ទ.១០២៨
  - ហែកបង្កាន់ដៃ ទ.១០២៨ ប្រគល់ឱ្យការីកុំព្យូទ័រ
  - ដកហូតបង្កាន់ដៃ ទ.១០២២ ចាស់ប្រសិនបើមាន កិបភ្ជាប់ជាមួយគល់ ទ.១០២៨
  - ណែនាំអ្នកស្នើសុំនោះ ឱ្យទៅជួបការីកុំព្យូទ័រ។
- **ចាត់ការីកុំព្យូទ័រឱ្យ៖**
  - ទាញយកទិន្នន័យរបស់អ្នកស្នើសុំ តាមរយៈស្នាមមេដៃ អត្តលេខ ឬលេខ អ.ខ ឬ ឯ.អ ឬនាមត្រកូល និងនាមខ្លួន
  - ផ្ទេរឈ្មោះ និងទិន្នន័យអ្នកស្នើសុំ ទៅការិយាល័យថ្មីក្នុងភូមិដែលគាត់រស់នៅ ដូចបានកំណត់ក្នុង ទ.១០២៨
  - ជម្រាបអ្នកស្នើសុំឱ្យផ្ទៀងផ្ទាត់ទិន្នន័យរបស់ខ្លួននៅលើម៉ូនីទ័រកុំព្យូទ័រ
  - ស្នើសុំអ្នកសុំប្តូរការិយាល័យផ្តល់ស្នាមម្រាមដៃបញ្ចូលក្នុងប្រព័ន្ធកុំព្យូទ័រ ដើម្បីបញ្ជាក់ថា គាត់ពិតជាបានស្នើសុំប្តូរការិយាល័យបោះឆ្នោត
  - ប្រគល់បង្កាន់ដៃ ទ.១០២៨ ឱ្យអ្នកស្នើសុំ។

### ឃ. ករណីអ្នកសុំចុះឈ្មោះបោះឆ្នោត បានចុះឈ្មោះបោះឆ្នោតរួចហើយ ក្នុងឃុំ សង្កាត់ផ្សេង

ប្រសិនបើអ្នកសុំចុះឈ្មោះបោះឆ្នោតឆ្លើយថា ធ្លាប់បានចុះឈ្មោះបោះឆ្នោតរួចហើយ ក្នុងឃុំ សង្កាត់ផ្សេង។

❖ ប្រធាន ក.ច.ប ត្រូវបន្តនីតិវិធីចុះឈ្មោះបោះឆ្នោត ដូចខាងក្រោម៖

☛ ពិនិត្យភាពមានសិទ្ធិចុះឈ្មោះបោះឆ្នោតរបស់អ្នកសុំចុះឈ្មោះបោះឆ្នោត ដូចខាងក្រោម ៖

- ផ្ទៀងផ្ទាត់ អ.ខ ឬ ឯ.អ
- មានអាយុ ១៨ឆ្នាំ ឡើងទៅគិតដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨
- មានលំនៅឋានឬទីសំណាក់ក្នុងឃុំ សង្កាត់ដែលសាមីខ្លួនត្រូវបោះឆ្នោត។

☛ ជម្រាបអ្នកសុំចុះឈ្មោះឱ្យទៅជួបអនុប្រធាន ក.ច.ប ហើយអនុប្រធានត្រូវហុច អ.ខ ឱ្យការីកុំព្យូទ័រស្វែងរកប្រវត្តិចុះឈ្មោះបោះឆ្នោតមុននឹងបន្ត នីតិវិធីចុះឈ្មោះបោះឆ្នោត។

❖ **ករណីរកពុំឃើញឈ្មោះក្នុងបញ្ជីបោះឆ្នោត**

អនុប្រធាន ក.ច.ប ឬជំនួយការដែលជួយការងារអនុប្រធាន និងការីកុំព្យូទ័រ ត្រូវអនុវត្តការចុះឈ្មោះបោះឆ្នោត ដូចករណីធម្មតា ដែលមានបញ្ជាក់ក្នុងជំហានទី៣ និងជំហានទី៤ ខាងលើ ។

❖ **ករណីអ្នកសុំចុះឈ្មោះបោះឆ្នោត ធ្លាប់បានចុះឈ្មោះបោះឆ្នោត និងមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ចុងក្រោយ**

អនុប្រធាន ក.ច.ប ឬជំនួយការដែលជួយការងារអនុប្រធាន ត្រូវសួរទីលំនៅក្នុងភូមិ ដើម្បីកំណត់បញ្ចូលឈ្មោះក្នុងការិយាល័យបោះឆ្នោត និងត្រូវបំពេញ ទ.១០២២ គ្មានអត្តលេខ សម្រាប់អ្នកផ្លាស់ប្តូរទីលំនៅ ដោយផ្អែកតាមទិន្នន័យក្នុង អ.ខ ឬ ឯ.អ ចុះហត្ថលេខា សរសេរឈ្មោះ និងបោះត្រា។ បន្ទាប់មកត្រូវប្រគល់ អ.ខ ឬ ឯ.អ និងឯកសារពាក់ព័ន្ធទៅ ការីកុំព្យូទ័រ និងណែនាំអ្នកសុំចុះឈ្មោះនោះ ឱ្យទៅជួបការីកុំព្យូទ័រ

☛ **ការីកុំព្យូទ័រ ត្រូវអនុវត្តដូចខាងក្រោម ៖**

- ត្រូវជ្រើសរើសយកឈ្មោះទីតាំង និងលេខកូដការិយាល័យបោះឆ្នោត
- ជូតសម្អាតមេដៃអ្នកស្នើសុំ បន្ទាប់មកធ្វើតេស្តស្នាមមេដៃទាំងសងខាង
- ថត អ.ខ ឬ ឯ.អ
- ជ្រើសរើសប្រវត្តិចុះឈ្មោះបោះឆ្នោត (ជ្រើសរើសយកពាក្យ ផ្ទេរចូលពីឃុំ សង្កាត់ផ្សេង)

- ស្វែងរកឈ្មោះ និងទិន្នន័យរបស់អ្នកសុំចុះឈ្មោះតាមអត្តលេខ លេខ អ.ខ ឬ ឯ.អ ឬនាមត្រកូល និងនាមខ្លួន
- ត្រូវផ្ទេរទិន្នន័យមួយចំនួនដែលរួមមាន អត្តលេខ លេខ អ.ខ ឬ ឯ.អ នាមត្រកូល និងនាមខ្លួន ភេទ ថ្ងៃ ខែ ឆ្នាំកំណើត
- បញ្ចូលអាសយដ្ឋានអ្នកសុំចុះឈ្មោះបោះឆ្នោត ដោយផ្អែកតាម អ.ខ ឬ ឯ.អ ឬ/និងឯកសារបញ្ជាក់ពីលំនៅឋាន ឬទីសំណាក់
- បំពេញភូមិឧបសម្ព័ន្ធ (ប្រសិនបើមាន)
- ជ្រើសរើសស្ថានភាពពិការភាពអ្នកចុះឈ្មោះបោះឆ្នោត(ប្រសិនបើមាន)
- ថតរូបចំពីមុខ
- ជួយកាន់មេដៃអ្នកសុំចុះឈ្មោះបោះឆ្នោតដាក់លើម៉ាស៊ីនស្កេន ដើម្បីយកស្នាមម្រាមដៃសាមីខ្លួនទាំងសងខាង ឆ្វេងចំនួន៤ដង និងស្តាំចំនួន៤ដង បញ្ចូលទៅក្នុងប្រព័ន្ធកុំព្យូទ័រ ដោយត្រូវយកស្នាមម្រាមដៃឆ្វេងមុន
- ថតឯកសារបញ្ជាក់ពីលំនៅឋាន ឬទីសំណាក់
- ជម្រាបអ្នកសុំចុះឈ្មោះបោះឆ្នោតឱ្យគាត់ផ្ទៀងផ្ទាត់ឈ្មោះ និងទិន្នន័យរបស់ខ្លួនដែលបានបង្ហាញនៅលើម៉ូនីទ័រកុំព្យូទ័រ
- ចុចលើប្រអប់រក្សាទុក (save) ទិន្នន័យអ្នកសុំចុះឈ្មោះបោះឆ្នោតទៅក្នុងប្រព័ន្ធកុំព្យូទ័រ និងចុចលើពាក្យយល់ព្រម
- ប្រគល់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត និង អ.ខ ឬឯ.អ ឬឯកសារបញ្ជាក់ពីលំនៅឋាន ឬទីសំណាក់ ជូនអ្នកសុំចុះឈ្មោះបោះឆ្នោត។

**ង. ករណីអ្នកសុំចុះឈ្មោះ បានចុះឈ្មោះបោះឆ្នោតរួចហើយ នៅឃុំ សង្កាត់ផ្សេង ក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត**

ប្រសិនបើអ្នកសុំចុះឈ្មោះបោះឆ្នោតឆ្លើយថា គាត់ធ្លាប់បានចុះឈ្មោះបោះឆ្នោតរួចហើយ នៅឃុំ សង្កាត់ផ្សេង ក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ប្រធាន ក.ច.ប ត្រូវបន្តអនុវត្តនីតិវិធីចុះឈ្មោះបោះឆ្នោត ដូចមានបញ្ជាក់ក្នុងជំហានទាំង៤ នៃការចុះឈ្មោះបោះឆ្នោត ដោយឱ្យអនុប្រធានក្រុមគូសធិកសម្គាល់ក្នុង ទ.១០២២ បន្ថែម ដើម្បីបញ្ជាក់ពីករណីនេះ និងដកហូតបង្កាន់ដៃ ទ.១០២២ ចាស់ (បើមាន) កិបភ្ជាប់និងគល់ ទ.១០២២ ថ្មី។

**ច. ករណីអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោត បានទទួលមរណភាពក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត**

ក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ប្រសិនបើមានរបាយការណ៍អំពីអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតបានទទួលមរណភាពមាន

ឯកសារសំអាងត្រឹមត្រូវ និងច្បាស់លាស់ ប្រធាន ក.ច.ប ត្រូវ៖

- ពិនិត្យឯកសារពាក់ព័ន្ធ
- ចាត់អនុប្រធានឱ្យបំពេញ ទ.១០២៥ និងរាយការណ៍ជូន កបឃ.ស ដើម្បីអនុវត្ត នីតិវិធីស្រង់ឈ្មោះដាក់ក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោត ដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោត។

**ឆ. ការអនុវត្តរបស់ ក.ច.ប លើរបាយការណ៍ស្តីពីការស្រង់ឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោត**

បន្ទាប់ពីទទួលបានរបាយការណ៍ស្តីពីការស្រង់ឈ្មោះអ្នកបោះឆ្នោត ដែលបានទទួលមរណភាព ឬត្រូវបានដកហូតជាបណ្តោះអាសន្ននូវសិទ្ធិបោះឆ្នោត ឬបានផ្លាស់លំនៅឋាន ឬទីសំណាក់ទៅឃុំ សង្កាត់ផ្សេង និងមានឯកសារសំអាងត្រឹមត្រូវ និង ច្បាស់លាស់ដែលទទួលបានពី លធ.ឌប ឬ កបឃ.ស ក.ច.ប ត្រូវត្រួតពិនិត្យផ្ទៀងផ្ទាត់តាមករណីនីមួយៗ ដោយផ្អែកលើឯកសារសំអាង និងទិន្នន័យក្នុងប្រព័ន្ធកុំព្យូទ័រ ប្រធាន អនុប្រធាន ក.ច.ប ត្រូវ៖

- ពិនិត្យលើបញ្ជីឈ្មោះអ្នកបោះឆ្នោត ដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោត ជាមួយនឹងឯកសារសំអាងឱ្យបានច្បាស់លាស់ តាមករណីនីមួយៗ និងទិន្នន័យមួយចំនួនក្នុងបញ្ជីបោះឆ្នោតចុងក្រោយ ដូចជាលេខ អ.ខ ឬ ឯ.អ នាមត្រកូល នាមខ្លួន ភេទ និងថ្ងៃខែឆ្នាំកំណើតជាដើម។
- ចាត់ការីកុំព្យូទ័រឱ្យផ្ទៀងផ្ទាត់បញ្ជីនេះជាមួយទិន្នន័យក្នុងប្រព័ន្ធកុំព្យូទ័របន្ថែមទៀត។
- បន្ទាប់មកប្រធាន និងអនុប្រធាន ក.ច.ប ត្រូវសម្រេចលើបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោត ហើយចាត់ឱ្យការីកុំព្យូទ័រស្នើសុំលុបឈ្មោះអ្នកទាំងនោះ តាមកម្មវិធីកុំព្យូទ័រដែលបានកំណត់មក គ.ជ.ប ដោយភ្ជាប់មកជាមួយនូវឯកសារសំអាង។

## VI. របៀប Backup សម្រាប់រក្សាទុកក្នុងកុំព្យូទ័រ

ជាទូទៅ ក.ច.ប ត្រូវថតចម្លងដាតាបេស ( Backup Database) ក្នុងមួយថ្ងៃឱ្យបានម្តងយ៉ាងតិច។ ធ្វើបែបនេះដើម្បីការពារ និងត្រៀមបម្រុងនៅពេលមានហេតុការណ៍ណាមួយកើតឡើង។ ដើម្បីចូលទៅក្នុងទម្រង់ថតចម្លងដាតាបេស(Backup Database) សម្រាប់រក្សាទុកប្រចាំថ្ងៃ យើងត្រូវអនុវត្តដូចខាងក្រោម៖

- ចុចលើពាក្យថា <u>រដ្ឋបាល</u> → ជ្រើសយកពាក្យ <u>Backup Database ប្រចាំថ្ងៃ</u>។ សូមមើលរូបទាំងពីរដូចខាងក្រោម៖




(រូបភាពទី៨)




(រូបភាពទី៩)

បន្ទាប់ពីឃើញផ្ទាំងដូចរូបទី៩ខាងលើហើយ យើងអាចដំណើរការ Backup បានហើយ។ ដើម្បីធ្វើការថតចម្លងជាតាបេស (Backup Database) ប្រចាំថ្ងៃយើងត្រូវអនុវត្តដូចខាងក្រោម ៖

- ចុចលើរូបភាព <u>**សាលាឃុំ-សង្កាត់**</u>
- ចុចលើប៊ូតុង <u>**យល់ព្រម**</u>
- រង់ចាំរហូតកម្មវិធីដំណើរការចប់ ១០០%
- ប្រសិនជាយើងចង់មើលទីតាំងរក្សាទុកឯកសារសូមចុចប៊ូតុង <u>**យល់ព្រម**</u>
- ប្រសិនជាយើងមិនមើលចង់មើលទីតាំងរក្សាទុកឯកសារទេ ហើយប្រតិបត្តិការចុះឈ្មោះបន្តសូមចុចប៊ូតុង <u>**បោះបង់**</u> ។សូមមើលរូប ដូចខាងក្រោម ៖




(រូបភាពទី១០)




(រូបភាពទី១១)




(រូបភាពទី១២)




(រូបភាពទី១៣)

## VII. **របៀប** Backup **សម្រាប់បញ្ជូនតាម** OwnCloud **ទៅឱ្យ គ.ជ.ប**

ក្នុងករណីទិន្នន័យអ្នកចុះឈ្មោះបោះឆ្នោតមិនអាចបញ្ជូនមក គ.ជ.ប តាមរយៈ Data transfer (VPN) យើងត្រូវថតចម្លងជាតាបេស (Backup Database) រួចបញ្ជូនតាមចំណាត់ការក្នុងចំណុចទី១ និងទី២ខាងក្រោម៖

- ថតចម្លង File Backup បន្ទាប់មករក្សាទុក (Save) ក្នុង Flash Drive រួចបញ្ជូនតាមរយៈ: OwnCloud ។
- ឬ បញ្ជូន Flash Drive ដែលបានរក្សាទុក (Save) File Backup នោះតាមឋានានុក្រមមក គ.ជ.ប ដោយការវេចខ្ចប់ត្រឹមត្រូវទៅតាមច្បាប់ បទបញ្ជា និងនីតិវិធីកំណត់ដើម្បីធានាសន្តិសុខសុវត្ថិភាពទិន្នន័យអ្នកចុះឈ្មោះ ដូច្នេះ ក.ច.ប ត្រូវបិទកញ្ចប់សុវត្ថិភាពហើយចុះហត្ថលេខានៅលើកញ្ចប់សុវត្ថិភាពនោះមុននឹងបញ្ជូនមក គ.ជ.ប (នាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត) ។ ក្នុងករណីនេះយើងត្រូវអនុវត្តដូចខាងក្រោម ៖
- ចុចលើពាក្យថា <u>**រដ្ឋបាល**</u> → ជ្រើសយកពាក្យ <u>Backup Database</u> ។ សូមមើលរូប ដូចខាងក្រោម ៖




(រូបភាពទី១៤)




(រូបភាពទី១៥)

បន្ទាប់ពីឃើញផ្ទាំងដូចរូបទី១៥ ខាងលើហើយ យើងអាចដំណើរការ Backup បានហើយ។ ដើម្បីធ្វើការថតចម្លងជាតាបេស (Backup Database) សម្រាប់បញ្ជូនតាម OwnCloud ទៅឱ្យ គ.ជ.ប យើងត្រូវអនុវត្តដូចខាងក្រោម៖

- ចុចលើរូបភាព **<u>គ.ជ.ប</u>**
- ចុចលើប៊ូតុង **<u>យល់ព្រម</u>**
- រង់ចាំរហូតកម្មវិធីដំណើរការចប់ ១០០%
- ប្រសិនជាយើងចង់មើលទីតាំងរក្សាទុកឯកសារសូមចុចប៊ូតុង **<u>យល់ព្រម</u>**
- ប្រសិនជាយើងមិនចង់មើលទីតាំងរក្សាទុកឯកសារទេ ហើយបន្តប្រតិបត្តិការចុះឈ្មោះ សូមចុចប៊ូតុង **<u>បោះបង់</u>**។ សូមមើលរូប ដូចខាងក្រោម ៖




(រូបភាពទី១៦)




(រូបភាពទី១៧)




(រូបភាពទី១៨)




(រូបភាពទី១៩)

បន្ទាប់ពីថតចម្លងដាតាបេស (Backup Database) ចប់រួចហើយសូមមើល File ដែលមានឈ្មោះ កូដឃុំ សង្កាត់ និងថ្ងៃខែឆ្នាំ Backup (ឧទាហរណ៍: NEC-12-037-2017-06-29-10-02-39) រួចរក្សាទុក (Save) ក្នុង USB Flash Drive បន្ទាប់មកអនុវត្តតាមចំណាត់ការទី១ ឬ ចំណាត់ការទី២ ខាងលើជាការស្រេច។

## VIII. គំនូសបំព្រួញរយៈពេលនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹង ក្នុងដំណាក់កាលនៃការចុះឈ្មោះបោះឆ្នោត



## IX. ការប្រើប្រាស់ទម្រង់បែបបទ

**ទ.១០០៩** គឺជាសេចក្តីសម្រេចបដិសេធការសុំចុះឈ្មោះបោះឆ្នោត ដែលប្រធាន ក.ច.ប ប្រើប្រាស់ក្នុងការបដិសេធការសុំចុះឈ្មោះបោះឆ្នោត ដែលមិនបានបំពេញតាមលក្ខខណ្ឌកំណត់។ ទ.១០០៩ បំពេញចំនួន ១ច្បាប់ ហើយចុះហត្ថលេខា បោះត្រានៅលើផ្នែកទី១ និងផ្នែកទី២ និងចំកណ្តាលកន្លែងហែកផ្តាច់ បន្ទាប់មកហែកផ្នែកទី២ ប្រគល់ឱ្យអ្នកសុំចុះឈ្មោះ និងផ្នែកទី១ ត្រូវរក្សាទុកដើម្បីដាក់ក្នុងស្បោង «ខ»។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

**សេចក្តីសម្រេចបដិសេធការសុំចុះឈ្មោះបោះឆ្នោត (ទ.១០០៩)** NºXXXXXXXX

**១. លក្ខណៈសម្គាល់នៃឃុំ សង្កាត់**

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ឈ្មោះ និងលេខកូដឃុំ សង្កាត់ | | | | | ឈ្មោះ និងលេខកូដរាជធានី ខេត្ត | | | |
| ឈ្មោះភូមិ | | | | | កាលបរិច្ឆេទនៃការសុំចុះឈ្មោះបោះឆ្នោត | / / | | |

**២. អត្តសញ្ញាណនៃអ្នកសុំចុះឈ្មោះបោះឆ្នោត**

| | | | | | |
|---|---|---|---|---|---|
| នាមត្រកូលនិងនាមខ្លួន | | ភេទ | | ថ្ងៃខែឆ្នាំកំណើត | / / |
| លំនៅឋាន ឬទីសំណាក់ : ផ្ទះលេខ ផ្លូវ ភូមិ ឃុំ សង្កាត់ | | | | | |

**៣. មូលហេតុនៃការបដិសេធការសុំចុះឈ្មោះបោះឆ្នោត**

☐ - គ្មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (សាមីខ្លួនត្រូវទៅជួបអាជ្ញាធរឃុំ សង្កាត់ ដើម្បីបំពេញបែបបទស្នើសុំឯកសារបញ្ជាក់អត្តសញ្ញាណ)

☐ - មិនគ្រប់អាយុបោះឆ្នោត

☐ - គ្មានឯកសារបញ្ជាក់លំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់ (សាមីខ្លួនត្រូវទៅជួបអាជ្ញាធរឃុំ សង្កាត់ សុំលិខិតបញ្ជាក់ទីលំនៅ)

☐ - ស្ថិតក្នុងស្ថានភាពជាប់ពន្ធនាគារ ឬត្រូវបានដកសិទ្ធិបោះឆ្នោត ឬ ☐ ជនវិកលចរិត ឬស្ថិតក្រោមអាណាព្យាបាលទូទៅ ដោយមានលិខិតបញ្ជាក់ពី ក្រសួង ស្ថាប័នមានសមត្ថកិច្ច

☐ - ការសុំចុះឈ្មោះក្រោយរយៈពេលកំណត់

**៤. សម្រាប់ក្រុមចុះឈ្មោះបោះឆ្នោត**

កាលបរិច្ឆេទ៖ ........./........./............ ហត្ថលេខាប្រធាន ក.ច.ប .............................. ត្រាការិយាល័យចុះឈ្មោះបោះឆ្នោត

- - - - - - - - - - - - - - - - - - - -


គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

**សេចក្តីសម្រេចបដិសេធការសុំចុះឈ្មោះបោះឆ្នោត (ទ.១០០៩)** NºXXXXXXXX

**១. លក្ខណៈសម្គាល់នៃឃុំ សង្កាត់**

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ឈ្មោះ និងលេខកូដឃុំ សង្កាត់ | | | | | ឈ្មោះ និងលេខកូដរាជធានី ខេត្ត | | | |
| ឈ្មោះភូមិ | | | | | កាលបរិច្ឆេទនៃការសុំចុះឈ្មោះបោះឆ្នោត | / / | | |

**២. អត្តសញ្ញាណនៃអ្នកសុំចុះឈ្មោះបោះឆ្នោត**

| | | | | | |
|---|---|---|---|---|---|
| នាមត្រកូលនិងនាមខ្លួន | | ភេទ | | ថ្ងៃខែឆ្នាំកំណើត | / / |
| លំនៅឋាន ឬទីសំណាក់ : ផ្ទះលេខ ផ្លូវ ភូមិ ឃុំ សង្កាត់ | | | | | |

**៣. មូលហេតុនៃការបដិសេធការសុំចុះឈ្មោះបោះឆ្នោត**

☐ - គ្មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (សាមីខ្លួនត្រូវទៅជួបអាជ្ញាធរឃុំ សង្កាត់ ដើម្បីបំពេញបែបបទស្នើសុំឯកសារបញ្ជាក់អត្តសញ្ញាណ)

☐ - មិនគ្រប់អាយុបោះឆ្នោត

☐ - គ្មានឯកសារបញ្ជាក់លំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់ (សាមីខ្លួនត្រូវទៅជួបអាជ្ញាធរឃុំ សង្កាត់ សុំលិខិតបញ្ជាក់ទីលំនៅ)

☐ - ស្ថិតក្នុងស្ថានភាពជាប់ពន្ធនាគារ ឬត្រូវបានដកសិទ្ធិបោះឆ្នោត ឬ ☐ ជនវិកលចរិត ឬស្ថិតក្រោមអាណាព្យាបាលទូទៅ ដោយមានលិខិតបញ្ជាក់ពី ក្រសួង ស្ថាប័នមានសមត្ថកិច្ច

☐ - ការសុំចុះឈ្មោះក្រោយរយៈពេលកំណត់

**៤. សម្រាប់ក្រុមចុះឈ្មោះបោះឆ្នោត**

កាលបរិច្ឆេទ៖ ........./........./............ ហត្ថលេខាប្រធាន ក.ច.ប .............................. ត្រាការិយាល័យចុះឈ្មោះបោះឆ្នោត


ទម្រង់បែបបទ ១០០៩ សម្រាប់បំពេញដោយ ក.ច.ប

- **ទ.១០១១** គឺជារបាយការណ៍ស្តីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត តាមការិយាល័យបោះឆ្នោតដែល ក.ច.ប ត្រូវបំពេញបន្ទាប់ពីបានបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។

ប្រសិនបើគ្មានបណ្តឹងតវ៉ា ដាក់នៅ កបឃ.ស ក្នុងរយៈពេល ៣ថ្ងៃ បន្ទាប់ពីថ្ងៃបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតទេ ក.ច.ប ត្រូវធ្វើរបាយការណ៍ ទ.១០១១ នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៨។

ប្រសិនបើមានបណ្តឹងតវ៉ាមួយ ឬច្រើន ត្រូវបានដាក់នៅ កបឃ.ស ក.ច.ប ត្រូវធ្វើរបាយការណ៍ ទ.១០១១ តាមការិយាល័យពាក់ព័ន្ធក្នុងឃុំ សង្កាត់ បន្ទាប់ពី កបឃ.ស បានសម្រេចដោះស្រាយបណ្តឹងចប់ ក.ច.ប ត្រូវធ្វើរបាយការណ៍នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៨។ ទ.១០១១ ប្រើប្រាស់ដូចខាងក្រោម ៖

*ទ.១០១១ ចំនួន ៤ច្បាប់*
- *១ ច្បាប់ ច្រកស្រោមសំបុត្រ សម្រាប់ដាក់ក្នុងកញ្ចប់ «ក»*
- *២ ច្បាប់ កិបភ្ជាប់នៅផ្នែកខាងក្រៅកញ្ចប់ «ក»*
- *១ ច្បាប់ ក.ច.ប រក្សាទុកជាឯកសារ ក្រោយមករក្សាទុកឯកសារ នៅសាលាឃុំ សង្កាត់*

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

**របាយការណ៍ស្តីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត (ទ.១០១១)**

**១. លក្ខណៈសម្គាល់នៃការិយាល័យបោះឆ្នោត**

| | | | | | |
|---|---|---|---|---|---|
| ឈ្មោះទីតាំង និងលេខកូដការិយាល័យបោះឆ្នោត | | | | | |
| ឈ្មោះ និងលេខកូដឃុំ សង្កាត់ | | | | | |
| ឈ្មោះ និងលេខកូដរាជធានី ខេត្ត | | | | | |

**២. របាយការណ៍ស្តីពីការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត**

| ចាប់ផ្តើមពីថ្ងៃទី / / ដល់ថ្ងៃទី / / | ចំនួនសរុប |
|---|---|
| ក- ចំនួនឈ្មោះអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោតឆ្នាំ២០១៧សរុប | |
| ខ- ចំនួនគល់បង្កាន់ដៃ ទ.១០២២ មានអត្តលេខសរុប (ចុះឈ្មោះថ្មី) | |
| គ- ចំនួនគល់បង្កាន់ដៃ ទ.១០២២ គ្មានអត្តលេខសរុប (ផ្ទេរចូលពីក្រៅឃុំ សង្កាត់) | |
| ឃ- ចំនួនគល់បង្កាន់ដៃ ទ.១០២៨ ប្តូរការិ. "ប្តូរចូល" ក្នុងឃុំ សង្កាត់សរុប | |
| ង- ចំនួនលុបឈ្មោះពីបញ្ជីបោះឆ្នោត (ស្លាប់ ដកសិទ្ធិ ផ្លាស់ចេញ ផ្ទេរចេញ និងប្តូរការិ. "ប្តូរចេញ" ក្នុងឃុំ សង្កាត់) | |
| ច- ចំនួនសរុបអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោតដែលបានពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០១៨ | |

សម្គាល់ : - ការផ្ទៀងផ្ទាត់ចំនួនក្នុងបញ្ជីតាមរូបមន្ត : ច = ( ក + ខ + គ + ឃ ) – ង

- ចំពោះការិយាល័យបោះឆ្នោតទើបបង្កើតថ្មីគ្មានចំនួនឈ្មោះអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោតឆ្នាំ២០១៧ ទេ ( ក = 0 )

| | |
|---|---|
| ឆ- ចំនួនកែតម្រូវឈ្មោះ និងទិន្នន័យសរុប | |

**៣. សម្រាប់គ្រូមចុះឈ្មោះបោះឆ្នោត**

កាលបរិច្ឆេទ៖ ........./.........../.......... ហត្ថលេខាប្រធាន ក.ច.ប..............................

ត្រាការិយាល័យចុះឈ្មោះបោះឆ្នោត

លេខទូរស័ព្ទ............................

**៤. សាក្សី : ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ( អាចសរសេរបន្ថែមខាងខ្នង )**

| ល.រ | នាមត្រកូល និងនាមខ្លួន | គណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ | ហត្ថលេខា | ល.រ | នាមត្រកូល និងនាមខ្លួន | គណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ | ហត្ថលេខា |
|---|---|---|---|---|---|---|---|
| ១ | | | | ៦ | | | |
| ២ | | | | ៧ | | | |
| ៣ | | | | ៨ | | | |
| ៤ | | | | ៩ | | | |
| ៥ | | | | ១០ | | | |

***កំណត់សម្គាល់ :*** *ក.ច.ប ត្រូវបំពេញទម្រង់បែបបទនេះចំនួន ៤ ច្បាប់ : ច្រកស្រោមសំបុត្រដាក់ក្នុងកញ្ចប់ "ក" ១ច្បាប់ កិបភ្ជាប់ទៅនឹងផ្នែកខាងក្រៅនៃកញ្ចប់ "ក" ចំនួន ២ ច្បាប់ និងរក្សាទុកជាឯកសាររបស់ឃុំ សង្កាត់ ១ ច្បាប់ ។*

ទម្រង់បែបបទ ១០១១ សម្រាប់បំពេញដោយ ក.ច.ប

☛ **<u>ទ.១០១២</u>** គឺជារបាយការណ៍សរុបស្តីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងឃុំសង្កាត់ ដែល ក.ច.ប ត្រូវបំពេញ ទ.១០១២ ចំនួន ៣ច្បាប់ ឱ្យរួចរាល់ នៅមុនពេលវេចខ្ចប់កញ្ចប់ «ក» ដាក់ក្នុងស្បោង«ខ»។ ទ.១០១២ ប្រើប្រាស់ ដូចខាងក្រោម ៖

*ទ.១០១២ ចំនួន ៣ច្បាប់*
- *២ច្បាប់ ច្រកស្រោមសំបុត្រ សម្រាប់ដាក់ក្នុងស្បោង «ខ» (ផ្ញើជូន គ.ជ.ប ចំនួន ១ច្បាប់ និង លធ.ខប ចំនួន ១ច្បាប់)*
- *១ច្បាប់ ក.ច.ប រក្សាទុកជាឯកសារ ក្រោយមកទុកជាឯកសារនៅសាលាឃុំ សង្កាត់*

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

**របាយការណ៍សរុបស្តីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១០១២)**

**១. លក្ខណៈសម្គាល់នៃឃុំ សង្កាត់**

| | | | | |
|---|---|---|---|---|
| ឈ្មោះ និងលេខកូដឃុំ សង្កាត់ | | | | |
| ឈ្មោះ និងលេខកូដរាជធានី ខេត្ត | | | | |
| ចំនួនការិយាល័យបោះឆ្នោតសរុប (មុនពេលចុះឈ្មោះ) | | ចំនួនការិយាល័យបង្កើតថ្មី | | |
| ចំនួនការិយាល័យមិនបានប្រើ | | ចំនួនការិយាល័យបានប្រើសរុប | | |

**២. ការិយាល័យចុះឈ្មោះបោះឆ្នោត និងសមាសភាពមន្ត្រីចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់**

ក- ការិយាល័យចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់មាន......................កន្លែង (ឈ្មោះភូមិអាចសរសេរបន្ថែមខាងខ្នង)

| | | | |
|---|---|---|---|
| ១-សាលាឃុំ សង្កាត់ | ២-ភូមិ | ៣-ភូមិ | ៤-ភូមិ |
| ៥-ភូមិ | ៦-ភូមិ | ៧-ភូមិ | ៨-ភូមិ |

ខ-សមាសភាពក្រុមចុះឈ្មោះបោះឆ្នោតមានចំនួន................នាក់

| | | | | | |
|---|---|---|---|---|---|
| ប្រធាន | | លេខទូរស័ព្ទ : | អនុប្រធាន | | លេខទូរស័ព្ទ : |
| សមាជិក | | សមាជិក | | សមាជិក | |

**៣. របាយការណ៍ស្តីពីការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់**

| ចាប់ផ្តើមពីថ្ងៃទី / / ដល់ថ្ងៃទី / / | ចំនួនសរុប |
|---|---|
| ក- ចំនួនឈ្មោះអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោតឆ្នាំ២០១៧ គ្រប់ការិ.បោះឆ្នោតក្នុងឃុំ សង្កាត់សរុប | |
| ខ- ចំនួនគល់បង្កាន់ដៃ ទ.១០២២ មានអត្តលេខ (ចុះឈ្មោះថ្មី) គ្រប់ការិ.បោះឆ្នោតក្នុងឃុំ សង្កាត់សរុប | |
| គ- ចំនួនគល់បង្កាន់ដៃ ទ.១០២២ គ្មានអត្តលេខ (ផ្ទេរចូលពីក្រៅឃុំ សង្កាត់) គ្រប់ការិ.បោះឆ្នោតក្នុងឃុំ សង្កាត់សរុប | |
| ឃ- ចំនួនគល់បង្កាន់ដៃ ទ.១០២៨ ប្តូរការិ. "ប្តូរចូល" ក្នុងឃុំ សង្កាត់គ្រប់ការិ.បោះឆ្នោតក្នុងឃុំ សង្កាត់សរុប | |
| ង- ចំនួនលុបឈ្មោះពីបញ្ជីបោះឆ្នោត ( ស្លាប់ ដកសិទ្ធិ ផ្លាស់ចេញ ផ្ទេរចេញ និងប្តូរការិ. "ប្តូរចេញ" ក្នុងឃុំ សង្កាត់) គ្រប់ការិ.បោះឆ្នោតក្នុងឃុំ សង្កាត់សរុប | |
| ច- ចំនួនអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោតដែលបានពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០១៨ គ្រប់ការិ.បោះឆ្នោតក្នុងឃុំ សង្កាត់សរុប | |

សម្គាល់ : - ការផ្ទៀងផ្ទាត់ចំនួនក្នុងបញ្ជីតាមរូបមន្ត : ច = ( ក + ខ + គ + ឃ ) – ង

| | |
|---|---|
| ឆ- ចំនួនកែតម្រូវឈ្មោះ និងទិន្នន័យគ្រប់ការិ.បោះឆ្នោតក្នុងឃុំ សង្កាត់សរុប | |
